រដ្ឋវ៉ាស៊ីនតោនរបស់អ្នក

# សៀវភៅស្តើងស្តីពី

# Health Home

... សម្រាប់ជីវិតកាន់តែល្អប្រសើរឡើង!



សេវាសម្របសម្រួលការថែទាំ **Health Home** សម្រាប់បុគ្គល ដែលមានសិទ្ធិទទួលបាន

Washington State Department of Social & Health Services

*Transforming lives*

Washington State Health Care Authority

Washington State Health Care Authority

[English] Language assistance services, including interpreters and translation of printed materials, are available free of charge. Call 1-877-501-2233 (TRS: 711).

[Amharic] የቋንቋ እገዛ አገልግሎት፣ አስተርጓሚ እና የሰነዶችን ትርጉም ጨምሮ በነጻ ይገኛል፡፡ 1-877-501-2233 (TRS: 711) ይደውሉ፡፡

[Arabic] خدمات المساعدة في اللغات، بما في ذلك المترجمين الفوريين وترجمة المواد المطبوعة، متوفرة مجاناً، اتصل على رقم 1-877-501-2233 (TRS: 711).

[Burmese] ဘာသာပြန်ဆိုသူများနှင့် ထုတ်ပြန်ထားသည့် စာရွက်စာတမ်းများဘာသာပြန်ခြင်းအပါအဝင် ဘာသာစကားအထောက်အကူဝန်ဆောင်မှုများကို အခမဲ့ရနိုင်ပါသည်။ 1-877-501-2233 (TRS: 711) ကိုဖုန်းခေါ်ဆိုပါ။

[Cambodian] សេវាជំនួយភាសា រួមមានទាំងអ្នកបកប្រែផ្ទាល់មាត់ និងការបកប្រែឯកសារបោះពុម្ព គឺអាចរកបានដោយឥតគិតថ្លៃ។ ហៅទូរស័ព្ទទៅលេខ 1-877-501-2233 (TRS: 711)។

[Chinese] 免费提供语言协助服务，包括口译员和印制资料翻译。请致电 1-877-501-2233 (TRS: 711)。

[Korean] 통역 서비스와 인쇄 자료 번역을 포함한 언어 지원 서비스를 무료로 이용하실 수 있습니다. 1-877-501-2233 (TRS: 711)번으로 전화하십시오.

[Laotian] ການບໍລິການດ້ານພາສາ, ລວມທັງນາຍແປພາສາ ແລະ ການແປເອກະສານຕີພິມ, ມີໄວ້ໃຫ້ຟຣີໂດຍບໍ່ຄິດຄ່າ. ໂທຫາເລກ 1-877-501-2233 (TRS: 711).

[Oromo] Tajajilli gargaarsa afaanii, nama afaan hiikuu fi ragaalee maxxanfaman hiikuun, kaffaltii malee ni argattu. 1-877-501-2233 (TRS: 711) irratti bilbilaa.

[Persian] خدمات کمک زبانی، از جمله مترجم شفاهی و ترجمه اسناد و مدارک (مطالب) چاپی، بصورت رایگان ارائه خواهد شد.با شماره 1-877-501-2233 (TRS: 711) تماس بگیرید.

[Punjabi] ਭਾਸ਼ਾ ਸਹਾਇਤਾ ਸੇਵਾਵਾਂ—ਦੁਭਾਸ਼ੀਏ ਅਤੇ ਪ੍ਰਿੰਟ ਕੀਤੀ ਹੋਈ ਸਮੱਗਰੀ ਦੇ ਅੰਨੁਵਾਦ ਸਮੇਤ—ਮੁਫ਼ਤ ਉਪਲੱਬਧ ਹਨ। 1-877-501-2233 (TRS: 711) 'ਤੇ ਕਾਲ ਕਰੋ।

[Romanian] Serviciile de asistență lingvistică, inclusiv cele de interpretariat și de traducere a materialelor imprimate, sunt disponibile gratuit. Apelați 1-877-501-2233 (TRS: 711).

[Russian] Языковая поддержка, в том числе услуги переводчиков и перевод печатных материалов, доступна бесплатно. Позвоните по номеру 1-877-501-2233 (TRS: 711).

[Somali] Adeego caawimaad luuqada ah, ay ku jirto turjubaano afka ah iyo turjumid lagu sameeyo waraaqaha la daabaco, ayaa lagu helayaa lacag la'aan. Wac 1-877-501-2233 (TRS: 711).

[Spanish] Hay servicios de asistencia con idiomas, incluyendo intérpretes y traducción de materiales impresos, disponibles sin costo. Llame al 1-877-501-2233 (TRS: 711).

[Swahili] Huduma za msaada wa lugha, ikiwa ni pamoja na wakalimani na tafsiri ya nyaraka zilizochapishwa, zinapatikana bure bila ya malipo. Piga 1-877-501-2233 (TRS: 711).

[Tagalog] Mga serbisyong tulong sa wika, kabilang ang mga tagapagsalin at pagsasalin ng nakalimbag na mga kagamitan, ay magagamit ng walang bayad. Tumawag sa 1-877-501-2233 (TRS: 711).

[Tigrigna] ተርጎምትን ናይ ዝተፅሓፉ ማተርያላት ትርጉምን ሓዊሱ ናይ ቋንቋ ሓገዝ ግልጋሎት፤ ብዘይ ምንም ክፍሊት ይርከቡ፡፡ ብ 1-877-501-2233 (TRS: 711) ደውሉ፡፡

[Ukrainian] Мовна підтримка, у тому числі послуги перекладачів та переклад друкованих матеріалів, доступна безкоштовно. Зателефонуйте за номером 1-877-501-2233 (TRS: 711).

[Vietnamese] Các dịch vụ trợ giúp ngôn ngữ, bao gồm thông dịch viên và bản dịch tài liệu in, hiện có miễn phí. Gọi 1-877-501-2233 (TRS: 711).

# សៀវភៅស្តីពី Health Home

# នៃរដ្ឋវ៉ាស៊ីនតោនរបស់អ្នក

## តើ Health Home គឺជាអ្វី?

Health Home មិនមែនជាទីកន្លែងមួយនោះទេ វាគឺជាឈុត សេវាសម្របសម្រួលការថែទាំ។ សេវាទាំងនេះត្រូវបានផ្តល់ជូន ដោយអ្នកសម្របសម្រួលការថែទាំណាម្នាក់ដែលនឹងជួយដល់ អ្នកក្នុងការប្រើប្រាស់សេវា និងជំនួយនានាដែលអ្នកទទួលបាននាពេលបច្ចុប្បន្នឲអស់ពីលទ្ធភាព។

សេវា Health Home ត្រូវបានរៀបចំឡើងដើម្បីផ្តល់ការទ្រទ្រង់ ដល់អ្នកចំពោះស្ថានភាពរ៉ាំរ៉ៃជាបន្តបន្ទាប់របស់អ្នក និងជួយអ្នកឱ្យ បំពេញតាមគោលដៅសុខភាពដែលអ្នកជ្រើសរើស។ សេវា Health Home ជួយធ្វើឲការសម្របសម្រួលទាំងតម្រូវការផ្នែក វេជ្ជសាស្រ្ត និងតម្រូវការសេវាសង្គមនានា ដូចជា សេវា និងការទ្រទ្រង់រយៈពេលវែង និងសុខភាពផ្នែកអាកប្បកិរិយា ដែលរួម បញ្ចូលទាំងវិបល្លាសក្នុងការប្រើប្រាស់សារធាតុនានាផងដែរនោះ មានភាពល្អប្រសើរឡើង។ កម្មវិធី Health Home មានបំណង បង្កើនលទ្ធភាពក្នុងការទទួលបាន និងបង្កើនការសម្របសម្រួលការថែទាំរបស់អ្នក។



## តើសេវា Health Home គឺជាអ្វី និងតើសេវាទាំងនេះអាចជួយអ្នកបានដោយវិធីណា?

- ការគ្រប់គ្រងការថែទាំគ្រប់ជ្រុងជ្រោយរួមបញ្ចូលការអភិវឌ្ឍ ផែនការសកម្មភាពសុខភាពផ្ទាល់ខ្លួនដែលមានគោលដៅ និង ដំណាក់កាលនានាដើម្បីសម្រេចគោលដៅទាំងនោះ។
- ការសម្របសម្រួលការថែទាំជួយធ្វើឲការប្រាស្រ័យទាក់ទង ជាមួយអ្នកផ្តល់សេវាថែទាំសុខភាព ក្រុមគ្រួសារ និងអ្នកមើល ថែទាំដទៃទៀតមានភាពប្រសើរឡើង។
- ការធ្វើផែនការផ្លាស់ប្តូរនឹងជួយដល់អ្នកនៅពេលអ្នកចាកចេញពី មន្ទីរពេទ្យ ឬទីកន្លែងថែទាំសុខភាព។
- សេវាទ្រទ្រង់បុគ្គល និងគ្រួសារធ្វើការសម្គាល់តួនាទីរបស់ សមាជិកនានានៅក្នុងគ្រួសារ ការទ្រទ្រង់មិនផ្លូវការ និងអ្នក មើលថែទាំក្នុងការជួយឲអ្នកសម្រេចតាមគោលដៅសុខភាពរបស់អ្នក។
- ការបញ្ជូនទៅកាន់សេវាទ្រទ្រង់សហគមន៍ និងសង្គមជួយដល់រឿង មួយចំនួនដូចជាការធ្វើដំណើរ ស្បៀងអាហារ និងកន្លែង ស្នាក់នៅ។
- ការលើកតម្កើងសុខភាពផ្តល់ការអប់រំ និងការបង្រៀនអំពី សុខមាលភាពដើម្បីជួយឲអ្នកសម្រេចតាមគោលដៅសុខភាពរបស់អ្នក។

## តើអ្នកណាខ្លះមានសិទ្ធិទទួលបានសេវា Health Home?

អ្នកបានទទួលសៀវភៅស្តីពី Health Home នេះពីព្រោះ អ្នកមានសិទ្ធិចូលរួមក្នុងកម្មវិធីនេះ។ សេវានានា គឺសម្រាប់បុគ្គល គ្រប់វ័យដែលមានស្ថានភាពរ៉ាំរ៉ៃដែលមានគុណសម្បត្តិគ្រប់គ្រាន់ យ៉ាងតិចមួយ។ ស្ថានភាពសុខភាពរ៉ាំរ៉ៃមួយចំនួនដែលធ្វើឲអ្នកណាម្នាក់មានសិទ្ធិចូលរួមក្នុងកម្មវិធីនេះ រួមមាន ៖

- ជំងឺមហារីក
- ស្ថានភាពផ្លូវដង្ហើមរ៉ាំរ៉ៃ
- ជំងឺវិកលចរិក ឬជំងឺភ្លេចភ្លាំងពេលវ័យចំណាស់
- ជំងឺទឹកនោមផ្អែម
- ជំងឺក្រពះ និងពោះវៀន
- ជំងឺបេះដូង
- ពិការភាពផ្នែកបញ្ញា ឬជំងឺផ្នែកបញ្ញា
- ស្ថានភាពសុខភាពផ្នែកអាកប្បកិរិយា
- ស្ថានភាពសាច់ដុំ និងឆ្អឹង
- ជំងឺប្រព័ន្ធប្រសាទ

## តើអ្នកសម្របសម្រួលការថែទាំ Health Home?

អ្នកសម្របសម្រួលការថែទាំ Health Home គឺជាអ្នកណាម្នាក់ ដែលអាចជួយអ្នកឲចូលរួមនៅក្នុងកម្មវិធី Health Home បាន។ អ្នកសម្របសម្រួលការថែទាំរបស់អ្នកនឹងធ្វើការជាមួយអ្នកដើម្បី ទទួលបានការថែទាំដែលត្រឹមត្រូវ ពីអ្នកផ្តល់ការថែទាំដែល ត្រឹមត្រូវ នៅពេលវេលា និងទីកន្លែងដែលត្រឹមត្រូវ។

អ្នកសម្របសម្រួលការថែទាំរបស់អ្នកនឹងទាក់ទងអ្នកដើម្បីរៀបរាប់ អំពីសេវាសម្របសម្រួលការថែទាំ និងឆ្លើយតបទៅនឹងសំណួរ ណាមួយដែលអ្នកមាន អំពីកម្មវិធី Health Home ។

## តើអ្នកនឹងទទួលបានសេវានានានៃកម្មវិធី Health Home បានដោយរបៀបណា?

មានជំហានមូលដ្ឋានបីដើម្បីចូលរួមនៅក្នុងកម្មវិធី Health Home ៖

**1. ត្រូវបានចាត់តាំងទៅកាន់កម្មវិធី Health Home ណាមួយ ៖** នៅពេលដែលអ្នកមានសិទ្ធិចូលរួម អ្នកនឹងត្រូវបានភ្ជាប់ទំនាក់ ទំនងទៅកាន់អង្គការដឹកនាំកម្មវិធី Health Home ដែលអង្គការ នោះនឹងចាត់តាំងឲអ្នកសម្របសម្រួលការថែទាំណាម្នាក់ទំនាក់ ទំនងទៅកាន់អ្នក។ អ្នកសម្របសម្រួលការថែទាំនោះនឹងឆ្លើយតប នឹងសំណួរនានារបស់អ្នក ហើយអ្នកអាចធ្វើសេចក្តីសម្រេចថាតើ អ្នកនឹងចូលរួមក្នុងកម្មវិធី Health Home នេះដែរឬទេ។

**2. *បំពេញទម្រង់ចែករំលែកព័ត៌មាន* និងទម្រង់យល់ព្រម ៖** អ្នកសម្របសម្រួលការថែទាំនឹងជួយអ្នកបំពេញទម្រង់យល់ព្រម ទទួលយកសេវានានារបស់ Health Home ដើម្បីផ្តល់ការ អនុញ្ញាតដល់ការចែករំលែកព័ត៌មានវេជ្ជសាស្ត្រ និងសេវាសង្គម របស់អ្នក។ ព័ត៌មានទាំងនេះនឹងត្រូវបានចែករំលែកតែជាមួយ អ្នកផ្តល់ការថែទាំ និងអ្នកដទៃទៀតដែលអ្នកបានជ្រើសរើសតែប៉ុណ្ណោះ។

**3. បំពេញផែនការ Health Home :** អ្នកនឹងអាចជ្រើសរើស គោលដៅសុខភាពផ្ទាល់ខ្លួនរបស់អ្នកបាន ដែលអ្នកសម្របសម្រួល ការថែទាំរបស់អ្នកនឹងរួមបញ្ចូលជម្រើសទាំងនោះចូលទៅក្នុង ផែនការសកម្មភាពសុខភាពរបស់អ្នក។ នេះនឹងត្រូវបានប្រើដើម្បីជួយអ្នក និងអ្នកសម្របសម្រួលការថែទាំរបស់អ្នកមើលថាតើអ្នកត្រូវការសេវាកម្ម និងធនធានបន្ថែមដែរឬយ៉ាងណា ដូចជា ៖

- តម្រូវការការថែទាំសុខភាព
- សេវា និងការទ្រទ្រង់រយៈពេលវែង
- សេវាសុខភាពផ្នែកអាកប្បកិរិយា
- ធនធានសហគមន៍
  - លំនៅដ្ឋាន
  - មធ្យោបាយធ្វើដំណើរ

អ្នកអាចស្នើសុំ និងរៀបចំការសួរសុខទុក្ខនាពេលអនាគតនៅពេល ណាមួយក៏បាន នៅកន្លែងណាមួយតាមជម្រើសរបស់អ្នក។

## តើអ្នកនៅតែទទួលបានសេវាថែទាំសុខភាពបច្ចុប្បន្នរបស់អ្នក និង អ្នកផ្តល់ការថែទាំផ្សេងទៀតដែរឬទេ?

បាទ/ចាស អ្នកនឹងនៅតែទទួលបានសេវា និងអ្នកផ្តល់សេវា បច្ចុប្បន្នរបស់អ្នកដដែល។ ក្នុងនាមជាផ្នែកមួយនៃសេវា Health Home អ្នកសម្របសម្រួលការថែទាំរបស់អ្នកអាចធ្វើការទំនាក់ ទំនងជាមួយអ្នកផ្តល់ការថែទាំនានាអំពីការធានារ៉ាប់រងដែលត្រូវបានសម្របសម្រួល និងការផ្លាស់ប្តូរការថែទាំនានា នៅពេល ដែលតម្រូវការរបស់អ្នកមានការប្រែប្រួល។

## តើអ្នកផ្តល់ការថែទាំនឹងដឹងដោយវិធីណាថាតើអ្នកស្ថិតនៅក្នុង កម្មវិធី Health Home ដែរឬទេ និងតើពួកគេត្រូវទាក់ទងអ្នកណា?

ពួកគេអាចប្រាប់បានតាមរយៈការត្រួតពិនិត្យ ProviderOne ឬ តាមរយៈការទំនាក់ទំនងទៅកាន់អាជ្ញាធរថែទាំសុខភាពតាមលេខ 1-800-562-3022។

## តើអ្នកត្រូវទូទាត់ប្រាក់សម្រាប់សេវា Health Home ដែរឬទេ?

ទេ សេវាទាំងនេះត្រូវបានផ្តល់ជូនអ្នកដោយឥតគិតថ្លៃ។

## តើអ្នកត្រូវធ្វើដូចម្តេចប្រសិនបើអ្នកមិនសប្បាយចិត្តចំពោះអ្នកសម្របសម្រួលការថែទាំរបស់អ្នក?

អ្នកអាចទំនាក់ទំនងទៅកាន់អង្គការសម្របសម្រួលការថែទាំ Health Home របស់អ្នក ដើម្បីស្នើសុំអ្នកសម្របសម្រួលការថែទាំម្នាក់ផ្សេងទៀត។

## តើអ្នកត្រូវធ្វើដូចម្តេចប្រសិនបើអ្នកផ្លាស់ទីលំនៅទៅកាន់តំបន់ណាមួយផ្សេងទៀតនៃរដ្ឋនេះ?

អ្នកអាចទទួលបានការចាត់តាំងអ្នកសម្របសម្រួលការថែទាំថ្មីម្នាក់។ គេនឹងទំនាក់ទំនងទៅកាន់អ្នកអំពីសេវានានាជាបន្តបន្ទាប់។

## តើអ្នកត្រូវធ្វើដូចម្តេចប្រសិនបើបាត់បង់ការធានារ៉ាប់រង Apple Health (Medicaid) ឬ Medicare?

ប្រសិនបើបាត់បង់ការធានារ៉ាប់រង Apple Health (Medicaid) អ្នកនឹងពុំមានសិទ្ធិទទួលបានសេវា Health Home បន្តទៀតឡើយ។

ប្រសិនបើបាត់បង់សិទ្ធិទទួលបាន Medicare របស់អ្នក និង មិនមែនជាសិទ្ធិទទួលបាន Apple Health របស់អ្នកនោះទេ អ្នកនៅតែអាចមានសិទ្ធិទទួលបានសេវា Health Home ដដែល។

## តើសិទ្ធិដាក់ពាក្យបណ្តឹង និងសិទ្ធិប្តឹងឧទ្ធរណ៍របស់អ្នកមានអ្វីខ្លះ?

អ្នកនៅតែបន្តមានសិទ្ធិធ្វើការប្តឹងតវ៉ា និងប្តឹងឧទ្ធរណ៍ចំពោះ Apple Health និង Medicare បច្ចុប្បន្នរបស់អ្នកដដែល។

## តើអ្នកត្រូវធ្វើដូចម្តេចប្រសិនបើអ្នកលែងចង់ចូលរួមនៅក្នុងកម្មវិធី Health Home បន្តទៀត?

អ្នកអាចនិយាយជាមួយអ្នកសម្របសម្រួលការថែទាំ Health Home របស់អ្នក និង ស្នើសុំចាកចេញពីកម្មវិធី។ ប្រសិនបើអ្នក ផ្លាស់ប្តូរចិត្តរបស់អ្នកនៅពេលក្រោយ អ្នកអាចហៅទូរស័ព្ទ ទៅកាន់អាជ្ញាធរថែទាំសុខភាពតាមលេខ 1-800-562-3022 និង ស្នើសុំចុះឈ្មោះចូលរួមក្នុងកម្មវិធី Health Home ឡើងវិញ។

## សម្រាប់ជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កា

ជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កាដែលមានសិទ្ធិ ចូលរួម អាចជ្រើសរើសចូលរួមក្នុងកម្មវិធី Health Home នៅ ពេលណាមួយក៏បាន ដោយធ្វើការទំនាក់ទំនងទៅកាន់អាជ្ញាធរថែទាំសុខភាព ដែលនឹងផ្ទៀងផ្ទាត់អំពីសិទ្ធិចូលរួម និងផ្តល់ជំនួយដល់ការចុះឈ្មោះចូលរួម។



### បុគ្គលដែលអ្នកត្រូវ ហៅទូរស័ព្ទទៅកាន់ក្នុងករណីមាន
### **ឯករណីមានវិបត្តិសុខភាព**

សម្រាប់ករណីគ្រាអាសន្នដែលគម្រាមកំហែងដល់អាយុជីវិត សូមហៅទូរស័ព្ទទៅកាន់

# **911។**

### នៅលើវែបសាយត៍

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធី Health Home សូមចូលទៅកាន់ **hca.wa.gov/free-or-low-cost-health-care/apple-health-medicaid-coverage/health-home**។

HCA ប្តេជ្ញាផ្តល់សិទ្ធិស្មើៗគ្នាក្នុងការទទួលបានសេវារបស់យើង។ ប្រសិនបើអ្នកត្រូវការកន្លែងស្នាក់នៅ ឬត្រូវការឯកសារនានាក្នុងទម្រង់មួយផ្សេងទៀត សូមហៅទូរស័ព្ទទៅកាន់ 1-800-562-3022។ សម្រាប់បុគ្គលដែលមានពិការភាពផ្នែកសោតវិញ្ញាណ ឬការនិយាយ សូមហៅទូរស័ព្ទទៅកាន់ 711 សម្រាប់សេវាឧបករណ៍ទទួល និងផ្តល់សញ្ញា។

Washington State Health Care Authority

P.O. Box 45535
Olympia, WA 98504-5535

HCA 22-851 CA (6/21) Cambodian